-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ :** ត្រូវបានប្តូរឈ្មោះទីរួមខេត្ត របស់ខេត្តកោះកុង មកជាស្រុក ស្មាច់មានជ័យ ដែលមានទីតាំងរដ្ឋបាល សាលា ស្រុកនៅភូមិ ស្ទឹង វែង ឃុំ ស្ទឹងវែង ។

**មាត្រា ២ :** ត្រូវបានប្តូរឈ្មោះសង្កាត់ចំនួន បី ចំណុះទីរួមខេត្ត មកជាឃុំចំនួន បី ចំណុះស្រុកស្មាច់មានជ័យ គឺ :

សង្កាត់ ១ មកជា ឃុំ ស្មាច់មានជ័យ

សង្កាត់ ២ មកជា ឃុំ ដងទង់

សង្កាត់ ៣ មកជា ឃុំ ស្ទឹងវែង

**មាត្រា ៣ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្ត កោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ។

**មាត្រា ៥ :** អនុក្រឹត្យនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥*

# អនុក្រឹត្យលេខ ២២ អនក្រ
# ស្តីពីការប្តូរឈ្មោះ ទីរួមខេត្ត សង្កាត់
# ក្នុងខេត្តពោធិ៍សាត់

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានប្តូរឈ្មោះ ទីរួមខេត្ត របស់ខេត្តពោធិសាត់ មកជាស្រុក សំពៅមាស ដែលមានទីតាំងរដ្ឋបាល សាលាស្រុកនៅភូមិ ពាលញែក ១ ឃុំ ផ្ទះព្រៃ ។

**មាត្រា ២ :** ត្រូវបានប្តូរឈ្មោះសង្កាត់ ចំនួន ប្រាំពីរ ចំណុះទីរួមខេត្ត មកជា ឃុំ ចំនួនប្រាំពីរ ចំណុះស្រុក សំពៅមាស ។

-សង្កាត់ រលាប មកជា ឃុំ រលាប

-សង្កាត់ ផ្ទះព្រៃ មកជា ឃុំ ផ្ទះព្រៃ

-សង្កាត់ កោះជុំ មកជា ឃុំ កោះជុំ

-សង្កាត់ លលកសរ មកជា ឃុំ លលកសរ

-សង្កាត់ ព្រៃញី មកជា ឃុំ ព្រៃញី

-សង្កាត់ ស្វាយអាត់ មកជា ឃុំ ស្វាយអាត់

-សង្កាត់ ចំរើនផល មកជា ឃុំ ចំរើនផល

**មាត្រា ៣ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្ត ពោធិសាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៥ :** អនុក្រឹត្យនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

www.pheakdeylaw.com